

អវសាន នៃ សេរីការជាតិ

អវសាន នៃ សេរីការជាតិ[1] ព្រោះ ប្រជនជនខ្មែរ សព្វថ្ងៃ ហាក់ បីដូច ជា នាំគ្នា ទទួលយក អាណានិគមយួន ជា លទ្ធហេតុ[2] សម្រាប់ ប្រជាជាតិ របស់ខ្លួន។ ជនជាតិយួន មករស់នៅ ខុសច្បាប់ ក្នុង ទឹកដីខ្មែរ រាប់លាននាក់ ប្តូរ រូបសាស្ត្រ នៃ សង្គមខ្មែរ ទាំងស្រុង នាំឲមើល លែងឃើញ នូវ អ្វី ដែល ជា ខ្លឹមសារជាតិ ខ្មែរ ពិតប្រាកដ ព្រោះ ជាតិសាសន៏ខ្មែរ កំពុង ក្លាយ ជា ជាតិ សាសន៏ ភាគតិច នៅក្នុង ប្រទេសខ្លួន ហើយ ពួក អ្នកដឹកនាំ និង អ្នកនយោបាយខ្មែរ មានអកប្បកិរិយា បីដូច ជា អ្នកបំរើ សុការ (serviteurs dociles) នៃ នយោបាយ គណបក្សកុម្មុយ និស្តយួន ក្នុង គោលដៅ នៃ ការបង្កើត សហព័ន្ធតណ្ឌូចិន នៅ ក្រោម ការត្រួតត្រា របស់វៀតណាម។ មួយវិញទៀត ជាតិសាស ន៏យួន មករស់ នៅ ស្រុកខ្មែរ គេ នាំចូល នូវ រ្ប្ជ្ជ្ជ្ជ ពាន់ឆ្នាំ របស់គេ មក ក្រប សង្គមខ្មែរ ទ្រុឌទ្រោម សព្វថ្ងៃនេះ ព្រោះ ខ្សោះ បដិសរីរ: (anticorps) សំរាប់ ការពារខ្លួន ត្បិត អ្នកដឹកនាំ ជាតិខ្មែរ តាំង ពី ឆ្នាំ ១៩៧៥ នាំគ្នា បន្ទ្រាបវា ដើម្បី ស្រួលដាំ រ្ប

[1] អវសាន នៃ សេរីការជាតិ ឬ អវសាន នៃ ការរំដោះជាតិ។

[2] លទ្ធហេតុ ជា ពាក្យ ដែល ខ្ញុំ ប្រើ បណ្តោះអាសន្ន ក្នុងន័យពាក្យបារាំង ថា fait accompli គឺ ហេតុការណ៏ ដែលមានកើតឡើង សព្វគ្រប់ ដែល គេនាំគ្នាទទួលស្គាល់វា។

អវសាន នៃ សេរីការជាតិ

ធម៌ថ្មី នៅក្នុង សង្គមខ្មែរ គឺ លទ្ធិកុម្មុយនិស្ត និង អ្វី ដែល វា ផ្ទុយពីប្រយោជន៍ខ្មែរ។

ក្រោយ ពី កិច្ចព្រមព្រៀង សន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ អ្នក នយោបាយខ្មែរ នាំគ្នា បន្ត ដើរ ដោយ អសម្បជញ្ញៈ លើផ្លូវ ផ្ទុយ ពីប្រយោជន៍ជាតិ ដែល នាំសម្រួល ដល់ នយោបាយយួន គឺ អាចឲគេ ទាញយកប្រយោជន៍ ពី កិច្ចព្រមព្រៀង សន្តិភាព នោះ ដើម្បី រក្សា ប្រយោជន៍យួន នៅ ស្រុកខ្មែរ តាម រយៈ អ្នក នយោបាយខ្មែរ រណបយួន និង អ្នករើរវាយ ថា អាច ឈ្នះ គណ បក្សកុម្មុនិស្តយួន ព្រោះ ខ្លួន មាន កិត្តិនាម លើ ឆាកអន្តរ ជាតិ និង ពួក អ្នកលួង យក យួនកុម្មុយនិស្ត ជា មិត្ត នយោបាយ និង មិត្តរួមអាវុធ ដើម្បី ច្បាំងនឹង ខ្មែរគ្នាឯង។ លទ្ធផល មហន្តរាយ នៃ គំនិតហួសវិស័យ នោះ វា ជម្រុញ ប្រជា ជាតិខ្មែរ ឲធ្លាក់ ទៅក្នុង រណ្តៅ សំរាប់ កប់ខ្មោច ដែល ពួក យួន កុម្មុយនិស្ត គេ ជីក ទុក តាំង ពី ឆ្នាំ ១៩៣០ គឺ ឆ្នាំ ដែល ពួក គេ បង្កើត គណបក្សកុម្មុយនិស្ត ឥណ្ឌូចិន។ កំហុស បន្ត របស់ ខ្មែរយើង សព្វថ្ងៃ ទាំង គណបក្សប្រឆាំង ទាំង ជនខ្មែរ ភាគ ច្រើន គឺ លែងមានជំនឿ ថា ខ្មែរយើង មាន សម្ថភាព ជា ប្រជា ជាតិ អាច រំដោះជាតិ ពី អាណានិគមយួន បាន ដោយ គ្រាន់ តែ នាំគ្នា ហ៊ាន ប្រើ សិទ្ធិ សេរីភាព របស់ខ្លួន ជា ពលរដ្ឋ។ ការ យក ការបោះឆ្នោត ជា មធ្យោបាយ វា ជា ផ្លូវ នៃ សេរីការជាតិ មួយពិត លុះត្រា តែ ខ្មែរយើង ហ៊ាន ការពារ លទ្ធផល បោះ ឆ្នោត តាម ឆន្ទៈ របស់ខ្លួន តែ បើ នាំគ្នា បោះឆ្នោត សំរាប់

អវសាន នៃ សេរីការជាតិ

ឲតែ គណបក្សប្រឆាំង យកវា ទៅធ្វើ ជា មធ្យោបាយ សំរាប់ ចរចា ចែក ប្រយោជន៏ ជាមួយ គណបក្សកាន់អំណាច ដូច នៅ ឆ្នាំ ២០១៣ គឺ ពិត ជា នាំគ្នា បោះឆ្នោត ជា ថ្មី សំរាប់ កប់ ប្រជា ជាតិខ្មែរ នៅក្នុង រណ្តៅ យួន ជីក ជា ពុំខាន។ ការទុក អាណា និគមយួន ជា បញ្ហា នៃ អាយុជីវិត នៃ ប្រជាជាតិខ្មែរ ចំពោះ ខ្មែរយើង មិនមែន ជា ពួជសាស្ត្រនិយម នោះឡើយ ព្រោះ ជាតិ សាសន៏ និមួយៗ អាច មាន សិទ្ធិ ពេញលេញ ស្របច្បាប់ ជាតិ និង អន្តរជាតិ សំរាប់ ការពារ ប្រជាជាតិខ្លួន។ ហើយ សេរីការ ជាតិ ក៏មិនមែន ជា អំពើ ប្រឆាំងនឹង សន្តិភាព នោះដែរ បើ សិនជា សន្តិភាព នោះ គេ បង្កើតឡើង សំរាប់ តែ បំផ្លាញ ប្រយោជន៏ ជាតិខ្មែរ។ បើ ខ្មែរយើង នាំគ្នា ជ្រើសរើស ការបោះ ឆ្នោត ជា មធ្យោបាយ នៃ ការរំដោះជាតិ គឺ ត្រូវធ្វើ ទាំងស្រុង គឺ ថា ១ វា មាន កំរិត ជា នយោបាយ រំដោះជាតិ ពិតប្រាកដ តាំង ខ្លួន ជា ម្ចាស់ និង ជា អ្នកទទួលខុសត្រូវ ប្រកបដោយ សេចក្តី ក្លាហាន ហ៊ាន ប្រទល់នឹង អំណាចយួន នៅស្រុកខ្មែរ។ បើ ខ្មែរ យើង នាំគ្នា ជ្រើសរើស ផ្លូវ បដិវត្ត អហិង្សា ជា មធ្យោបាយ គឺ ថា ត្រូវនាំគ្នា ធ្វើ ប្រជាបាតុកម្ម អហិង្សា តឡូវនេះ ប្រឆាំងនឹង អំណាចយួន ដែល មាន គណបក្សកាន់អំណាច ជា រណប និង ជា ដៃ នៃ ឃាតកម្ម សម្លាប់ខ្មែរ។ ត្រប់រូបភាព នៃ ដំណើរ ញាញើតញាញើម នៅចំពោះមុខ បញ្ហា នៃ អាយុជីវិតជាតិ នេះ គឺ ច្បាស់ ជា អវសាន នៃ សេរីការជាតិ នោះឯង។

មានសេចក្តីក្លាហាន ហើយ ហ៊ានធ្វើ ទើប អាចឈ្នះបាន.